# របាយការណ៍ក្រសួងការបរទេសសហរដ្ឋអាមេរិក

# របាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ ២០១៥

# ប្រទេសកម្ពុជា - (លំដាប់ថ្នាក់ទី ២ ក្នុងបញ្ជីតាមដាន)

កម្ពុជាគឺជាប្រទេសប្រភព ជាប្រទេសឆ្លងកាត់ និងជាប្រទេសគោលដៅសំរាប់បុរស ស្ត្រី និង កុមារ ដែលរង គ្រោះដោយការចាប់បង្ខំអោយធ្វើពលកម្ម និងការជួញដូរផ្លូវភេទ ។ ប្រជាជនកម្ពុជាពេញវ័យនិង កុមារកម្ពុជាធ្វើ ចំណាកស្រុកទៅប្រទេសដទៃទៀតនៅក្នុងតំបន់ ហើយក្នុងចំនួនកាន់តែច្រើនឡើង ទៅមជ្ឈឹមបូព៌ា ដើម្បីរកការងារធ្វើ។ ពួកគេជាច្រើននាក់បានរងគ្រោះដោយការជួញដូរផ្លូវភេទ ឬការបង្ខំអោយធ្វើពលកម្មធ្ងន់ធ្ងរក្នុងទូកនេសាទ ក្នុងវិស័យកសិកម្ម តាមការដ្ឋានសំណង់ នៅតាមរោងចក្រឬបំរើនៅក្នុងផ្ទះដូចជាទាសករ ។ កុមារនៅក្នុងគ្រួសារក្រីក្រងាយរងគ្រោះខ្លាំងដោយការបង្ខំអោយធ្វើពលកម្ម ដែលរួមមានការបង្ខំអោយធ្វើជាឈ្នួលបំរើតាមផ្ទះ និងត្រូវបានបង្ខំអោយដើរសុំទាន នៅប្រទេសថៃ និងប្រទេសវៀតណាម។ បុរសខ្មែរក្នុងចំនួនកាន់តែច្រើនត្រូវបានគេជ្រើសរើសអោយទៅធ្វើការនៅប្រទេសថៃលើទូកនេសាទ ហើយបន្ទាប់មក ត្រូវបានបង្ខំអោយធ្វើការ នៅលើទូកនេសាទថៃ នៅក្នុងដែនទឹកអន្តរជាតិ។ ជនរងគ្រោះខ្មែរដែលគេចចេញពីទំរង់បែបនេះនៃការកេងប្រវ័ញ្ច ត្រូវបានគេរកឃើញនៅប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី Mauritius ហ្វីជី សេណេហ្កាល់ និងអាហ្វ្រិកខាងត្បូង។ បុរសខ្មែរបាននិយាយពីការធ្វើបាបយ៉ាងខ្លាំងដោយអ្នកគ្រប់គ្រងទូកថៃ ការជ្រើសរើសអោយធ្វើការដោយការបោកបញ្ឆោត ការអោយថ្លៃឈ្នួលមិនគ្រប់ ហើយនិងការបង្ខំអោយនៅលើទូករាប់ឆ្នាំ។ អង្គការមិនមែនរដ្ឋាភិបាលរាយការណ៍ថា នារីនៅតាមជនបទត្រូវបានគេដើរជ្រើសរើសក្រោមលេសកុហក អោយធ្វើដំណើរទៅប្រទេសចិន ដើម្បីរៀបការជាមួយបុរសជនចិន ហើយមានខ្លះត្រូវបានបង្ខំអោយធ្វើការនៅក្នុងរោងចក្រ ឬបង្ខំអោយធ្វើពេស្យា។

ខេត្តទាំងអស់នៃប្រទេសកម្ពុជាគឺជាប្រភពនៃការជួញដូរមនុស្ស។ ជាទូទៅ ការជួញដូរផ្លូវភេទមានលក្ខណៈលាក់បាំង។ កុមារនិងនារីខ្មែរនិងវៀតណាមមកពីតំបន់ជនបទចូលទីក្រុង និងតំបន់ទេសចរណ៍ ដែលនៅទីនោះ ពួកគេត្រូវរងការជួញដូរផ្លូវភេទនៅតាមផ្ទះបន បៀហ្គាដិន កន្លែងម៉ាសា កន្លែងខារ៉ាអូខេ និងកន្លែងមិនទាក់ទងនឹងពាណិជ្ជកម្ម។ របាយការណ៍មួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលចេញនៅឆ្នាំ ២០១៣ បានពិនិត្យមើលការមានកុមារច្រើន នៅក្នុងចំណោមមនុស្សដែលត្រូវបានគេជួញដូរផ្លូវភេទ នៅតាមកន្លែងបំរើផ្លូវភេទ នៅតាមទីក្រុងចំនួន ៣ ហើយបានរកឃើញថា កុមារមានចំនួន ៨,២% នៃជនរងគ្រោះទាំងនោះ។ របាយការណ៍នេះបានសន្និដ្ឋានថា ចំនួននេះបង្ហាញអោយឃើញការធ្លាក់ចុះយ៉ាងច្រើន នៅក្នុងទំរង់នៃការជួញដូរផ្លូវភេទលើកុមារ គិតចាប់តាំងពីការចេញរបាយការណ៍មុនៗ ពីអង្គការ ស្ថាប័ននានា នៅឆ្នាំ ១៩៩៧ និងឆ្នាំ ២០០០។ អង្គការមិនមែនរដ្ឋាភិបាលដដែលបាននិយាយថា ការវាយតំលៃកាលពីខែមិនា ឆ្នាំ ២០១៥ បានរកឃើញថា ចំនួនកុមារដែលស្ថិតនៅក្នុងចំណោមជនរងគ្រោះទាំងនេះមានការធ្លាក់ចុះមកត្រឹម ២,២%។ លទ្ធផលទាំងនេះមិនទាន់ត្រូវបានគេបោះពុម្ពផ្សាយទេ នៅដំណាច់រយៈពេលនៃរបាយការណ៍នេះ។ បុរសកម្ពុជាគឺជាប្រភពតំរូវការធំជាងគេលើពេស្យាចារកុមារ។ តែបុរសមកពីប្រទេសដទៃនៅអាស៊ី សហរដ្ឋអាមេរិក អូស្ត្រាលី អាហ្វ្រិកខាងត្បូង និងអឺរ៉ុប ធ្វើដំណើរមកកម្ពុជា ដើម្បីធ្វើទេសចរណ៍ផ្លូវភេទលើកុមារ។ ស្ត្រីនិងកុមារវៀតណាម ដែលមានច្រើនជាជនរងគ្រោះដោយទាសភាពបំណុល ធ្វើដំណើរមកកម្ពុជា ហើយបានរងគ្រោះដោយការជួញដូរផ្លូវភេទ។ តំបន់ស្វាយប៉ាកនៅក្រៅក្រុងភ្នំពេញ ដែលជាប្រភពសំខាន់នៃការជួញដូរផ្លូវភេទលើកុមារ បច្ចុប្បន្ន ក្នុងពេលខ្លះ គឺជាជាកន្លែងឆ្លងកាត់សំរាប់ជនរងគ្រោះដោយការជួញដូរផ្លូវភេទ ពីប្រទេសវៀតណាម ដែលត្រូវបានកេងប្រវ័ញ្ចនៅតាមសណ្ឋាគារ និងកន្លែងដទៃទៀត នៅភ្នំពេញ។ អង្គការមិនមែន

រដ្ឋាភិបាលរាយការណ៍ថា ជនរងគ្រោះជាជនជាតិវៀតណាមត្រូវបានដឹកឆ្លងកាត់ប្រទេសកម្ពុជាដោយក្រុមឧក្រិដ្ឋជន មុនពេលត្រូវបានកេងប្រវ័ញ្ច នៅប្រទេសថៃ និងប្រទេសម៉ាឡេស៊ី។ ជនប្រព្រឹត្តការជួញដូរច្រើនតែជាសមាជិកសហគមន៍ ឬគ្រួសារ ឬក៏បណ្តាញតូចៗនៃឈ្មួញកណ្តាលដែលធ្វើសកម្មភាពដោយខ្លួនឯង។ មន្ត្រីពុករលួយនៅកម្ពុជា ថៃ និងម៉ាឡេស៊ីរួមគ្នាជាមួយឈ្មួញកណ្តាលដែលជ្រើសរើសពលករ ដើម្បីសំរួលដល់ការដឹកជញ្ជូនជនរងគ្រោះឆ្លងកាត់ព្រំដែន។ អ្នកសង្កេតការណ៍ក្នុងស្រុកនិយាយថា មន្ត្រីពុករលួយច្រើនធ្វើអោយរាំងស្ទះដល់ដំណើរជឿនលឿននៅក្នុងករណីដែលក្នុងនោះជនប្រព្រឹត្តការជួញដូរត្រូវបានគេជឿថា មានទំនាក់ទំនងសេដ្ឋកិច្ច បទល្មើស ឬទំនាក់ទំនងនយោបាយជាមួយមន្ត្រីរដ្ឋាភិបាល។

រដ្ឋាភិបាលកម្ពុជាមិនបានគោរពបានពេញលេញតាមបទដ្ឋានអប្បបរិមាសំរាប់ការបំបាត់ការជួញដូរ មនុស្សទេ ។ ទោះជាយ៉ាងណាក្តី ក៏រដ្ឋាភិបាលកំពុងតែខិតខំច្រើនគួរសមក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ។ ទោះបីជាមានវិធានការទាំងនេះក្តី ក៏រដ្ឋាភិបាលមិនបានបង្ហាញអោយឃើញភស្តុតាងនៃការបង្កើនការខិតខំជារួមក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្សអោយបានច្រើនលើសឆ្នាំកន្លងទៅដែរទេ។ ដូច្នេះ ប្រទេសកម្ពុជាត្រូវបានដាក់អោយស្ថិតនៅក្នុងចំណាត់ថ្នាក់លេខ ២ ក្នុងបញ្ជីតាមដាន សំរាប់ឆ្នាំទី ៣ ជាប់គ្នាមកនេះ។ ប្រទេសកម្ពុជាត្រូវបានផ្តល់អោយនូវការលើកលែងពីការបញ្ចុះដល់ចំណាត់ថ្នាក់លេខ ៣ ពីព្រោះរដ្ឋាភិបាលកម្ពុជាបានសរសេរផែនការមួយ ហើយបើផែនការនេះត្រូវបានអនុវត្ត វាគឺជាការខិតខំដ៏ធំមួយក្នុងការឈានទៅបំពេញតាមបទដ្ឋានអប្បបរិមានៃការលុបបំបាត់ការជួញដូរមនុស្ស ហើយកំពុងគ្រោងប្រើធនធានគ្រប់គ្រាន់ ដើម្បីអនុវត្តផែនការនេះ។ រដ្ឋាភិបាលបានបន្តកាត់ទោស និងដាក់ទោសជនប្រព្រឹត្តការជួញដូរ រួមទាំងករណីមួយដែលពាក់ពាន់នឹងការបង្ខំអោយបុរសកម្ពុជាធ្វើការនៅលើទូកនេសាទ។ រដ្ឋាភិបាលមិនបានកាត់ទោស ឬដាក់ទោសលើមន្ត្រីឃុបឃិតណាមួយ ហើយមិនបានចាត់វិធានការដាក់ពិន័យលើអតីតមេនគរបាលប្រឆាំងការជួញដូរមនុស្ស ដែលការដាក់ទោសរបស់តុលាការទៅលើជននេះ កាលពីឆ្នាំ ២០១១ ពីបទជួញដូរមនុស្សត្រូវបានលុបចោលទៅវិញ នៅក្នុងសវនាការមួយដែលបិទទ្វារ ហើយមិនប្រកាសអោយដឹង របស់តុលាការកំពូល នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍លើកមុននេះ។ អាជ្ញាធរមូលដ្ឋានបានរកឃើញ ហើយបញ្ជូនជនរងគ្រោះដោយការជួញដូរផ្លូវភេទក្នុងស្រុកចំនួន ៣២៦ នាក់ទៅអោយអង្គការមិនមែនរដ្ឋាភិបាល។ ទោះបីជាមានកំណើននៃជនរងគ្រោះជាបុរស និងជនរងគ្រោះខ្មែរដែលរងការកេងប្រវ័ញ្ចនៅបរទេសក្តី ក៏រដ្ឋាភិបាលមិនបានធ្វើអោយមានភាពជឿនលឿនក្នុងការផ្តល់ការការពារដល់ក្រុមទាំងនេះដែរ។ រដ្ឋាភិបាលបានដាក់ចុះនូវផែនការសកម្មភាពជាតិថ្មីមួយសំរាប់ប្រយុទ្ធប្រឆាំងនឹងការជួញដូរ។ យ៉ាងណាក្តី ក៏រដ្ឋាភិបាលមិនបានអនុម័តលើពង្រាងគោលការណ៍សំរាប់កំណត់អត្តសញ្ញាណជនរងគ្រោះ ហើយក៏មិនបានចេញគោលការណ៍ណែនាំជាផ្លូវការ ដែលអនុញ្ញាតអោយមានការប្រើបច្ចេកទេសស៊ើបអង្កេតបែបសំងាត់ នៅក្នុងការស៊ើបអង្កេតការជួញដូរដែរ។ ចំណុចទាំងពីរនេះនៅជាគំនិតផ្តួចផ្តើម ដែលមិនត្រូវបានដាក់ចុះអោយអនុវត្ត អស់រយៈពេលជាច្រើនឆ្នាំមកហើយ។

**អនុសាសន៍សំរាប់ប្រទេសកម្ពុជា៖** អនុម័តនិងអនុវត្តពិធីសារទូទាំងប្រទេស ដើម្បីរកមើលជនរងគ្រោះនៅក្នុងចំណោមជនដែលងាយរងគ្រោះ បង្កើនការផ្តល់សេវាដល់ជនរងគ្រោះជាបុរស ពិសេសបុរសដែលរងការកេងប្រវ័ញ្ចក្នុងការនេសាទ បង្កើនការខិតខំក្នុងការស៊ើបអង្កេត និងនាំខ្លួនយកមកកាត់ទោស ដាក់ទោស និងដាក់ទណ្ឌកម្មចំពោះជនល្មើសក្នុងការជួញដូរ ទាំងអ្នកជួញដូរពលករ ទាំងអ្នកជួញដូរផ្លូវភេទ ជនដែលទិញការរួមភេទជាមួយកុមារ និងមន្ត្រីឃុបឃិត ចេញប្រកាសឬការណែនាំផ្លូវការដទៃទៀតដែល

អនុញ្ញាតអោយមានការប្រើបច្ចេកទេសស៊ើបអង្កេតសំងាត់ នៅក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរ បង្កើតអោយមាននិតិវិធីជាប្រព័ន្ធ ហើយកំណត់ធនធានសំរាប់ជួយជនរងគ្រោះខ្មែរ តាមរយៈបេសកកម្មការទូតនៅបរទេស ឬនៅក្នុងប្រទេសដែលគ្មានតំណាងទូតកម្ពុជា អនុវត្តប្រព័ន្ធមួយសំរាប់តាមដាន ប្រមូល និងរាយការណ៍ទិន្នន័យស្តីពីការអនុវត្តច្បាប់ប្រឆាំងការជួញដូរ និងការខិតខំក្នុងការការពារជនរងគ្រោះ លៃថវិកាគ្រប់គ្រាន់សំរាប់អនុវត្តផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស រៀបចំគោលនយោបាយសំរាប់ប្រគល់ការគ្រប់គ្រងជាផ្លូវការលើជនរងគ្រោះជាកុមារ ទៅអោយអង្គការមិនមែនរដ្ឋាភិបាល បង្កើនការខិតខំធ្វើអោយដំណើរការរបស់តុលាការយកចិត្តទុកដាក់ពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ជនរងគ្រោះ ដូចជាតាមរយៈការផ្តល់ការការពារដល់សាក្សី និងជំរើសលើសំណងទូទាត់ ហើយបន្តយុទ្ធនាការលើកកំពស់ការយល់ដឹងរបស់សាធារណជន ដើម្បីកាត់បន្ថយតំរូវការជួញដូរផ្លូវភេទ និងទេសចរណ៍ផ្លូវភេទលើកុមារ ដោយផ្តោតជាសំខាន់លើការលុបបំបាត់តំរូវការរបស់មនុស្សក្នុងប្រទេស។

## ការនាំខ្លួនយកមកកាត់ទោស

រដ្ឋាភិបាលខ្វះទិន្នន័យពេញលេញ ស្តីពីការងារពង្រឹងការអនុវត្តច្បាប់ តែព័ត៌មានដែលត្រូវបានប្រមូលមកពីប្រភពផ្សេងៗបង្ហាញថា មានភាពជឿនលឿនតិចតួច នៅក្នុងការនាំខ្លួនជនល្មើសមកកាត់ទោស និងដាក់ទោស។ ច្បាប់ដែលត្រូវបានដាក់ចេញនៅឆ្នាំ ២០០៨ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទមាននិយាយច្បាស់ពីបទល្មើសជួញដូរជាច្រើនក្នុងមាត្រាចំនួន ១២ ក្នុងចំណោមមាត្រាចំនួន ៣០ ក្នុងច្បាប់នេះ។ ច្បាប់នេះហាមប្រាមគ្រប់ទំរង់ទាំងអស់នៃការជួញដូរមនុស្ស ហើយចែងពីការដាក់ទោសចំពោះបទល្មើស ដែលមានភាពម៉ឺងម៉ាត់គ្រប់គ្រាន់ និងស្របតាមទោសសំរាប់បទឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀតដូចជាការរំលោភសេពសន្ថវៈ។ អាជ្ញាធរមិនសូវយល់ពីច្បាប់ប្រឆាំងការជួញដូរទេ ហើយបានប្រើបញ្ញាតិនៃក្រមព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាសំរាប់កាត់ទោសក្នុងករណីបទល្មើសជួញដូរមនុស្ស។ រដ្ឋាភិបាលមិនបានផ្តល់ទិន្នន័យពេញលេញស្តីពីការងារពង្រឹងការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរទេ។ អាជ្ញាធរបាននិយាយថា បាននាំមកកាត់ទោសនូវជនសង្ស័យក្នុងការជួញដូរចំនួន ២១ នាក់ តែប្រភពឯករាជ្យបានរាយការណ៍ថា រដ្ឋាភិបាលបានកាត់ទោសជនសង្ស័យយ៉ាងហោចណាស់ ៥៣ នាក់ នៅក្រោមច្បាប់ប្រឆាំងនឹងការជួញដូររបស់ខ្លួន ឬបញ្ញាតិប្រហាក់ប្រហែលនេះនៅក្នុងក្រមព្រហ្មទណ្ឌ ដោយរួមទាំង ៤១ នាក់ពីបទជួញដូរផ្លូវភេទ និង ១២ នាក់ ពីបទជួញដូរកំលាំងពលកម្ម។ របាយការណ៍របស់រដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការមិនមែនរដ្ឋាភិបាលបង្ហាញថា រដ្ឋាភិបាលបានដាក់ទោសលើជនប្រព្រឹត្តការជួញដូរផ្លូវភេទយ៉ាងហោចណាស់ចំនួន ២២ នាក់ និងជនប្រព្រឹត្តការជួញដូរកំលាំងពលកម្មចំនួន ៧ នាក់ ដែលជាចំនួនកើនពីចំនួនប្រព្រឹត្តការជួញដូរដែលត្រូវបានដាក់ទោសដោយតុលាការចំនួន ១៨ នាក់ កាលពីឆ្នាំមុន។ ជនល្មើសបានទទួលទោសពី ២ ទៅ ១៥ ឆ្នាំក្នុងពន្ធនាគារ។ នៅខែមេសា ឆ្នាំ ២០១៤ រដ្ឋាភិបាលបានដាក់ទោសលើចិនតៃវ៉ាន់ចំនួន ៦ នាក់ពីបទចាប់បង្ខំបុរសខ្មែររាប់រយនាក់អោយធ្វើពលកម្ម នៅក្នុងផ្នែកនេសាទ។ ម្នាក់កំពុងជាប់ក្នុងពន្ធនាគារ ហើយ ៥ នាក់ទៀតមិនទាន់ចាប់ខ្លួនបាននៅឡើយ។

រដ្ឋាភិបាលកម្ពុជាបានបន្តរៀបចំនិងបើកការបណ្តុះបណ្តាលក្រោមជំនួយរបស់ម្ចាស់អំណោយស្តីពីការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរ សំរាប់មន្ត្រីតុលាការ និងសមត្ថកិច្ចចំនួនជាង ២ ៥០០ រូប។ អង្គការក្នុងស្រុក និងមន្ត្រីខ្លះមើលឃើញសេចក្តីត្រូវការជា

បន្ទាន់លើបច្ចេកទេសប្រមូលភស្តុតាងទំនើប ដែលរួមមានការស៊ើបអង្កេតជាសំងាត់ ការបន្ថយការពឹងផ្អែកលើការឆ្លើយរបស់សាក្សី ហើយសំរបតាមលក្ខណៈដែលកាន់តែមានភាពលាក់បាំងច្រើននៃការជួញដូរផ្លូវភេទ នៅកម្ពុជា។ រដ្ឋាភិបាលមិនបានចេញការណែនាំ ដែលផ្តល់ការយល់ព្រមច្បាស់លាស់លើការប្រមូលភស្តុតាងដោយសំងាត់ក្នុងករណីជួញដូរមនុស្សទេ។ ដោយសារគ្មានការណែនាំនេះ ព្រះរាជអាជ្ញាបដិសេធសំណើរបស់អ្នកស៊ើបអង្កេត ដែលជាការបង្ខំអោយគេបិទការស៊ើបអង្កេតខ្លះចោល។ អង្គការមិនមែនរដ្ឋាភិបាល មួយបាននិយាយថា មន្ត្រីកម្រនាំយកមកកាត់ទោសណាស់នូវករណីជួញដូរឆ្លងព្រំដែន ទោះបីជាជនរងគ្រោះជាច្រើនចង់ធ្វើការ សហការជាមួយមន្ត្រីក៏ដោយ។

អំពើពុករលួយដែលមានជាទូទៅនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងរដ្ឋាភិបាលកម្ពុជារឹតត្បិតយ៉ាងខ្លាំងដល់លទ្ធភាពរបស់មន្ត្រី ម្នាក់ៗ ក្នុងការចាប់អោយជនប្រព្រឹត្តការជួញដូរទទួលខុសត្រូវ។ អ្នកជំនាញការក្នុងស្រុកបានរាយការណ៍ពីករណីជោគជ័យមួយ ដែល ក្នុងនោះ អាជ្ញាធរបាននាំខ្លួនមកកាត់ទោស ហើយដាក់ទោសលើជនប្រព្រឹត្តការជួញដូរផ្លូវភេទចំនួន ៦ នាក់ ដែលត្រូវបានគេដឹងថា កន្លងមក បានទទួលការការពារពីការចាប់ខ្លួនដោយអ្នកដឹកនាំនៃកងរាជអាវុធហត្ថ។ រដ្ឋាភិបាលបានស៊ើបអង្កេតការចោទប្រកាន់ពី បទពុករលួយលើមន្ត្រីនគរបាលម្នាក់ ហើយបានបណ្តេញមន្ត្រីនោះចេញពីតំណែង។ រដ្ឋាភិបាលមិនបាននាំយកមកកាត់ទោស ឬដាក់ ទោសបុគ្គលិករដ្ឋណាមួយដែលសមគំនិតក្នុងការជួញដូរ ឬចាត់វិធានការដាក់ទណ្ឌកម្មណាមួយប្រឆាំងនឹងអតីតមេនគរបាលប្រឆាំង ការជួញដូរមនុស្សរាជធានីភ្នំពេញ ដែលការដាក់ទោសនៅឆ្នាំ ២០១១ ទៅលើគាត់ពីបទជួញដូរមនុស្សត្រូវបានលុបចោលទៅវិញ នៅ ក្នុងសវនាការបិទទ្វារ និងដោយគ្មានការប្រកាសរបស់តុលាការកំពូល នៅក្នុងអំឡុងពេលនៃរបាយការណ៍លើកមុនទេ។

**ការការពារ** ( Protection )

រដ្ឋាភិបាលបានបន្តរកមើលជនរងគ្រោះ ហើយបញ្ជូនគេទៅអោយអង្គការមិនមែនរដ្ឋាភិបាល តែការការពារជនរងគ្រោះនៅ តែមិនទាន់គ្រប់គ្រាន់នៅឡើយ។ រដ្ឋាភិបាលមិនបានអនុម័តគោលការណ៍ណែនាំសំរាប់ធ្វើអោយមានប្រព័ន្ធជាបទដ្ឋានទូទាំងប្រទេស សំរាប់កំណត់ជនរងគ្រោះក្នុងចំណោមក្រុមមនុស្សដែលងាយរងគ្រោះជាងគេទេ។ រដ្ឋាភិបាលបានឆ្រឹកកម្មវិធីសាកល្បងមួយ ដើម្បី ស្ទង់ប្រសិទ្ធភាពនៃគោលការណ៍ណែនាំទាំងនេះ នៅក្នុងខេត្តចំនួន ៥ តែទោះបីជាមានការរៀបចំតាក់តែងជាង ៥ ឆ្នាំហើយក្តី ក៏ គោលការណ៍ណែនាំនេះនៅមិនទាន់បង្ហើយនៅឡើយទេ។ ដោយមានជំនួយពីអង្គការអន្តរជាតិមួយ រដ្ឋាភិបាលបានបន្តដំណើរការ មជ្ឈមណ្ឌលទទួលអោយស្នាក់នៅបណ្តោះអាសន្នមួយនៅប៉ោយប៉ែត ដែលនៅទីនោះ រដ្ឋាភិបាលបានរកមើលជនរងគ្រោះដោយការ ជួញដូរក្នុងចំណោមជនចំណាកស្រុកចំនួនប្រហែល ៥០ ០០០ នាក់ ដែលត្រូវបានបញ្ជូនត្រឡប់ពីប្រទេសថៃវិញ នៅឆ្នាំ ២០១៤។ ជនរងគ្រោះចំនួន ៣៣៦ នាក់ត្រូវបានរកឃើញ ហើយត្រូវបានផ្តល់ជំរកបណ្តោះអាសន្ន។ រដ្ឋាភិបាលបានដំណើរការកន្លែងជំរក បណ្តោះអាសន្នមួយនៅភ្នំពេញសំរាប់ទទួលជនរងគ្រោះដោយការជួញដូរ និងបទល្មើសផ្សេងទៀតជាស្ត្រី និងកុមារី ហើយបានបញ្ជូន ជនរងគ្រោះដោយការជួញដូរទៅកន្លែងជំរករបស់អង្គការមិនមែនរដ្ឋាភិបាល ដែលភាគច្រើនមើលថែទាំជនរងគ្រោះដោយសារការធ្វើ បាបផ្សេងៗ តែរដ្ឋាភិបាលមិនបានផ្តល់ជំនួយអ្វីថែមទៀតដល់ជនរងគ្រោះឡើយ។ មិនដូចក្នុងឆ្នាំកន្លងទៅទេ អាជ្ញាធរមិនបានផ្តល់ ស្ថិតិពេញលេញស្តីពីចំនួនជនរងគ្រោះដែលខ្លួនបានជួយ ឬបញ្ជូនទេ ហើយចំនួនសរុបនៃជនរងគ្រោះដែលត្រូវបានរកឃើញ ឬជួយ

ដោយរដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាល ក៏មិនត្រូវបានដឹងដែរ។ នគរបាលមូលដ្ឋានបានបញ្ជូនជនរងគ្រោះដោយការជួញដូរផ្លូវភេទចំនួន ៣២៦ នាក់ទៅស្ថាប័នខេត្តសំរាប់ការបញ្ជូនបន្តទៅអង្គការមិនមែនរដ្ឋាភិបាល។ ចំនួននេះមានការកើនឡើងពីចំនួន ១៥១ នាក់ នៅក្នុងអំឡុងពេលនៃរបាយការណ៍ឆ្នាំមុន។ អង្គការមិនមែនរដ្ឋាភិបាលចំនួន ២ បានផ្តល់ជំរក និងសេវាដល់ជនរងគ្រោះចំនួន ២២២ នាក់ ដែលគ្មានការជួយពីរដ្ឋាភិបាល។ រដ្ឋាភិបាលមិនបានតាក់តែងគោលនយោបាយសំរាប់ផ្ទេរការគ្រប់គ្រងលើជនរងគ្រោះជាកុមារ អោយទៅអង្គការមិនមែនរដ្ឋាភិបាលទេ ដែលជាការធ្វើអោយអង្គការដែលបានទទួលជនរងគ្រោះជាកុមារ ងាយរងនឹងការប្តឹងទៅតុលាការ។ ពេលខ្លះ មន្ត្រីរដ្ឋាភិបាលបានបញ្ជូនកុមារត្រឡប់ទៅក្នុងបរិយាកាសដែលប្រឈមនឹងគ្រោះថ្នាក់ខ្លាំង បើសិនជាសមាជិកគ្រួសារមិនទទួលពួកគេជាបណ្តោះអាសន្នអោយស្នាក់នៅ។ ទោះបីមានជនរងគ្រោះភេទប្រុសច្រើនក្តី តែការជួយសំរាប់ក្រុមនេះមានត្រឹមតែការផ្តល់ជំរកនៅតាមកន្លែងជំរកដែលខ្វះបទពិសោធន៍នៅក្នុងការថែទាំជនរងគ្រោះតែប៉ុណ្ណោះ។ រដ្ឋាភិបាលកម្ពុជាតំរូវអោយជនរងគ្រោះជាជនបរទេស ត្រូវនាំទៅមាតុភូមិគេវិញ ហើយមិនបានផ្តល់ជំរើសផ្លូវច្បាប់ផ្សេងក្រៅពីការបញ្ជូនពួកគេទេ ក្នុងករណីដែលគេជួបប្រទះការលំបាក ឬការធ្វើបាបនៅពេលទៅដល់ប្រទេសកំណើតរបស់គេវិញ។ ជនរងគ្រោះចំនួន ២១ នាក់ត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ។

រដ្ឋាភិបាលគ្មាននិតិវិធីគ្រប់គ្រាន់សំរាប់ជួយជនរងគ្រោះដែលរកឃើញនៅបរទេសទេ។ បេសកកម្មទូតនៅបរទេសខ្វះថវិកាឬសមត្ថភាពគ្រប់គ្រាន់ សំរាប់ផ្តល់ជំនួយចាំបាច់ ឬបញ្ជូនជនរងគ្រោះត្រឡប់មកមាតុប្រទេសវិញ។ ជនរងគ្រោះដែលត្រូវបានរកឃើញនៅក្នុងប្រទេសដែលគ្មានតំណាងទូតកម្ពុជា រឹតតែមិនសូវទទួលបានការជួយថែមទៀត។ អង្គការមិនមែនរដ្ឋាភិក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិបានជួយក្នុងការធ្វើមាតុភូមិនិវត្តន៍នៃជនរងគ្រោះដោយការជួញដូរពលកម្ម ពីប្រទេសថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងប្រទេសចិន ដោយរួមទាំងមនុស្ស ៩៣ នាក់ ដែលត្រូវបានចាប់បង្ខំអោយធ្វើការនៅលើទូកនេសាទរបស់អ្នករកស៊ី។ អាជ្ញាធរកម្ពុជាបានទទួលជនរងគ្រោះចំនួន ៤៣៦ នាក់ ដែលត្រូវបានរកឃើញ ហើយត្រូវបានបញ្ជូនត្រឡប់មកវិញដោយរដ្ឋាភិបាលថៃ និងរដ្ឋាភិបាលវៀតណាម។ គ្មានរបាយការណ៍ថា មនុស្សដែលត្រូវបានរកឃើញថាជាជនរងគ្រោះ ត្រូវបានគេដាក់ទណ្ឌកម្មដោយសារការរងការជួញដូរទេ តែកង្វះនិតិវិធីផ្លូវការសំរាប់កំណត់ជនរងគ្រោះធ្វើអោយគេមិនអាចរកឃើញជនរងគ្រោះជាច្រើន ហើយធ្វើអោយពួកគេប្រឈមនឹងការដាក់ទណ្ឌកម្ម។ មន្ត្រីច្រើនតែខ្វះកន្លែងការិយាល័យគ្រប់គ្រាន់ សំរាប់ដាក់អោយជនរងគ្រោះ និងជនល្មើសនៅដាច់ពីគ្នាក្នុងពេលសំភាសន៍។ ប្រព័ន្ធច្បាប់ពុករលួយនិងខ្សោយរបស់ប្រទេសកម្ពុជា និងកង្វះការការពារគ្រប់គ្រាន់សំរាប់ជនរងគ្រោះ និងសាក្សី ដែលត្រូវបានធ្វើអោយមានលក្ខណៈកាន់តែអាក្រក់ឡើងដោយដំណើរការកាត់ក្តីយូរ និងការភ័យខ្លាចការសងសឹកដោយជនប្រព្រឹត្តការជួញដូរ បង្កជាឧបសគ្គមិនអោយជនរងគ្រោះមានចិត្តចង់ធ្វើសហប្រតិបត្តិការនៅក្នុងករណីរបស់គេ។ ជនរងគ្រោះដែលគ្រួសាររបស់គេបានទទួលសំណងទូទាត់ក្រៅតុលាការ ពីជនប្រព្រឹត្តការជួញដូរ ច្រើនតែផ្លាស់ប្តូរចំលើយជាកសិណរបស់គេ ដែលជាការធ្វើអោយរាំងស្ទះដល់ការនាំខ្លួនជនល្មើសមកកាត់ទោសបានដោយជោគជ័យ។ ជាគោលការណ៍ ជនរងគ្រោះអាចទទួលបានសំណងទូទាត់ តែការនេះត្រូវរងកំហិតព្រំដែនដោយលក្ខខ័ណ្ឌតាមផ្លូវច្បាប់ដែលចែងថា ការទូទាត់សងអាចត្រូវបង់អោយតែនៅពេលជនព្រឹត្តការជួញដូរចេញពីពន្ធនាគារវិញតែប៉ុណ្ណោះ។

**ការការពារកុំអោយកើតមាន**

( Prevention )

រដ្ឋាភិបាលកម្ពុជាបានបន្តការខិតខំមិនសូវជាច្រើនទេក្នុងការការពារកុំអោយមានការជួញដូរមនុស្ស។ គណៈកម្មាធិការអន្តរក្រសួង និងលេខាធិការដ្ឋានរបស់គណៈកម្មាធិការនេះ បានបន្តដឹកនាំការខិតខំប្រឆាំងការជួញដូរ ហើយនៅខែកុម្ភៈ ឆ្នាំ ២០១៥ បានបង្កើតផែនការសកម្មជាតិជាតិថ្មីមួយ។ គណៈកម្មាធិការនេះនៅតែខ្វះថវិកាគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពអោយមានប្រសិទ្ធភាព ថ្វីបើថវិការបស់ខ្លួនគ្រោងនឹងមានកំណើននៅឆ្នាំ ២០១៥ ក្តី។ គណៈកម្មាធិការនៅតាមមូលដ្ឋានសំរបសំរួលការងារនៅថ្នាក់ខេត្ត ហើយជាលើកដំបូងហើយដែលរដ្ឋាភិបាលបានផ្តល់ថវិកាខ្លះដល់គណៈកម្មាធិការចំនួន ៥ ដែលបានធ្វើការស្នើសុំ។ រដ្ឋាភិបាលមិនបានដាក់ទណ្ឌកម្មលើក្រុមហ៊ុនជ្រើសរើសពលកររកស៊ីខុសច្បាប់ទេ ដែលអាចនាំដល់ការជួញដូរមនុស្ស។ ដោយមានការជួយពីម្ចាស់អំណោយបរទេស និងម្ចាស់អំណោយក្នុងស្រុក រដ្ឋាភិបាលបានផលិត និងផ្សព្វផ្សាយឯកសារបោះពុម្ព ធ្វើការផ្សាយតាមវិទ្យុ និងការតាំងបង្ហាញតាមផ្ទាំងប៉ាណូ និងផ្ទាំងរូបទាក់ទងនឹងគ្រោះថ្នាក់នៃការជួញដូរមនុស្សដែលមានទំរង់ផ្សេងៗ។ ក្រសួងទេសចរណ៍បានបន្តការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងការធ្វើការបណ្តុះបណ្តាល ធ្វើផ្ទាំងប៉ាណូ និងក្រដាសចែកចាយ ដែលមានបំណងកាត់បន្ថយតំរូវការលើជំនួញផ្លូវភេទ និងទេសចរណ៍ផ្លូវភេទលើកុមារ ថ្វីបើការខិតខំទាំងនេះសំដៅលើទេសចរផ្លូវភេទបរទេស ជាជាងមនុស្សនៅក្នុងប្រទេស ដែលជាប្រភពធំនៃតំរូវការលើជំនួញផ្លូវភេទលើកុមារក្តី។ អាជ្ញាធរបាននិយាយថា បានចាប់ខ្លួនជនបរទេសចំនួន ១២ នាក់ ហើយតុលាការបានដាក់ទោសលើពួកគេចំនួន ២ នាក់ និងពលរដ្ឋខ្មែរចំនួន ៧ នាក់ ពីបទទិញការរួមភេទជាមួយកុមារ។ កាលពីឆ្នាំទៅ តុលាការបានដាក់ទោសទៅលើមនុស្សតែចំនួន ៧ នាក់ទេ ។ អ្នកជំនាញក្នុងស្រុកបាននិយាយថា គេនៅតែមានកង្វល់លើការខកខានរបស់រដ្ឋាភិបាលក្នុងការធ្វើការស៊ើបអង្កេត ឬដាក់ទោសទៅលើជនបរទេសដែលទិញការរួមភេទជាមួយកុមារអោយបានត្រឹមត្រូវ។ រដ្ឋាភិបាលបានធ្វើការបណ្តុះបណ្តាលស្តីពីការប្រឆាំងការជួញដូរមនុស្សដល់អ្នកការទូតបុគ្គលិកយោធារបស់ខ្លួន មុនពេលពួកគេចេញទៅបំពេញការងាររថែរក្សាសន្តិភាពនៅបរទេស។